# វ៉ាក់សាំងបង្ការជំងឺអុតស្វាយ ( Varicella Vaccine )

## ១- ដូចម្តេចដែលហៅថាជំងឺអុតស្វាយ?

ជំងឺអុតស្វាយជាជំងឺឆ្លងម្យ៉ាងដែលគេសង្កេតឃើញកើតមានជាញឹកញាប់លើកុមារ។ ជាទូទៅជំងឺនេះមានទំរង់ស្រាល ប៉ុន្តែពេលខ្លះវាអាចមានសភាពធ្ងន់ធ្ងរ ជាពិសេសលើកុមារតូចៗ និងមនុស្សធំ។

ជំងឺអុតស្វាយអាចចំលងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបាន តាមរយៈខ្យល់បរិយាកាស រឺដោយការប៉ះពាល់ផ្ទាល់ជាមួយទឹករងៃ នៅលើស្បែកពងទឹករបស់អ្នកជំងឺ។

រោគសញ្ញានៃជំងឺអុតស្វាយ រួមមាន ស្បែកឡើងកន្ទួលមានពងទឹករមាស់ ក្តៅខ្លួន និងអស់កំលាំងល្ហិតល្ហៃ។ វាអាចបណ្តាលអោយមានការបង្ករោគលើស្បែកធ្ងន់ធ្ងររហូតដល់មានស្លាកស្នាម ហើយពេលខ្លះ វាអាចបង្កអោយមានផលវិបាកធ្ងន់ធ្ងរ ដូចជារលាកសួត ការប៉ះពាល់ដល់ខួរក្បាល រឺអាចបណ្តាលអោយស្លាប់បាត់បង់ជីវិតផងដែរ។

## ២- វ៉ាក់សាំងបង្ការជំងឺអុតស្វាយ

មនុស្សភាគច្រើនដែលបានទទួលវ៉ាក់សាំងបង្ការជំងឺអុតស្វាយ ពុំមានកើតជំងឺអុតស្វាយឡើយ។ ប៉ុន្តែគេសង្កេតឃើញមនុស្សមួយចំនួននៅតែកើតជំងឺអុតស្វាយនេះ បើទោះបីជាពួកគេបានទទួលវ៉ាក់សាំងបង្ការជំងឺនេះរួចហើយក្តី តែស្ថានភាពជំងឺមានសភាពស្រាល ដោយគ្រាន់តែមានពងទឹកតិចតួច និងក្តៅខ្លួន រួចជាសះស្បើយទៅវិញយ៉ាងឆាប់រហ័ស។

## ៣- តើអ្នកណាខ្លះគួរទទួលវ៉ាក់សាំងនេះ? ហើយគួរធ្វើនៅពេលណា?

វ៉ាក់សាំងនេះត្រូវផ្តល់ចំនួន ២ដូស ដល់កុមារ ដែលពុំធ្លាប់កើតជំងឺនេះ៖

- ដូសទី១ នៅចន្លោះអាយុ ពី ១២-១៥ ខែ
- ដូសទី២ នៅចន្លោះអាយុ ពី ៤-៦ ឆ្នាំ

កុមារដែលមានអាយុចាប់ពី ១៣ឆ្នាំ ឡើងទៅ រឺមនុស្សពេញវ័យដែលពុំទាន់បានកើតជំងឺអុតស្វាយនេះ ត្រូវទទួលថ្នាំបង្ការនេះចំនួន ២ដូស ដោយគំលាតនៃការចាក់ដូសទី១ និងដូសទី២ ត្រូវមានរយៈពេលយ៉ាងតិច ២៨ ថ្ងៃ។

អ្នកដែលដែលបានចាក់វ៉ាក់សាំងនេះហើយ តែពុំបានត្រឹមត្រូវតាមក្បួនខ្នាត និងពុំទាន់បានកើតជំងឺអុតស្វាយនេះ ត្រូវទទួលថ្នាំបង្ការនេះបន្ថែម ១-២ដូស យោងទៅតាមអាយុជាក់ស្តែងរបស់អ្នកជំងឺ។

## ៤- តើអ្នកណាខ្លះដែលមិនអាចទទួលវ៉ាក់សាំងនេះបាន? តើអ្នកណាខ្លះដែលត្រូវពន្យាពេលក្នុងការចាក់វ៉ាក់សាំងនេះ?

- អ្នកដែលធ្លាប់មានប្រតិកម្មធ្ងន់ធ្ងរជាមួយវ៉ាក់សាំងអុតស្វាយនេះ រឺអ្នកដែលមានប្រតិកម្មជាមួយ gelatin រឺថ្នាំ Neomycin មិនអាចទទួលវ៉ាក់សាំងអុតស្វាយនេះបានជាដាច់ខាត
- អ្នកដែលកំពុងមានជំងឺ
- ចំពោះស្ត្រីមានផ្ទៃពោះ ការចាក់ថ្នាំបង្ការនេះត្រូវផ្អាកសិន
- ស្ត្រីដែលបានទទួលថ្នាំបង្ការនេះមិនត្រូវមានផ្ទៃពោះឡើយ រហូតដល់ ១ខែ យ៉ាងតិច ក្រោយពេលចាក់
- អ្នកដែលមានប្រព័ន្ធភាពស៊ាំខ្សោយ ដូចជាអ្នកជំងឺអេដស៍ អ្នកមានជំងឺប្រព័ន្ធភាពស៊ាំ អ្នកព្យាបាលដោយថ្នាំស្តេរ៉ូអ៊ីតរយៈពេលយូរ អ្នកមានជំងឺមហារីក ជាដើម ក៏មិនអាចទទួលវ៉ាក់សាំងនេះបានដែរ។
- អ្នកដែលមានប្រវត្តិបញ្ចូលឈាមក្នុងពេលថ្មីៗនេះ

## ៥- តើវ៉ាក់សាំងនេះ អាចបណ្តាលអោយមានផលវិបាកអ្វីខ្លះ?

ដូចឱសថផ្សេងទៀតដែរ វ៉ាក់សាំងអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរ ដូចជាប្រតិកម្មអាលែកស៊ីជាដើម។ ប៉ុន្តែករណីដែលអាចបង្កឲ្យមានផលវិបាកធ្ងន់ធ្ងរមានតិចតួចបំផុត។ ផលវិបាកដែលអាចកើតឡើងរួមមាន៖

- ការឡើងក្រហម រឺឈឺត្រង់កន្លែងចាក់
- ក្តៅខ្លួន
- ឡើងកន្ទួលរមាស់
- ប្រតិកម្មអាលែកស៊ីធ្ងន់ធ្ងរ (ប៉ុន្តែកម្រជួបប្រទះ)

**ប្រសិនបើមានសញ្ញាប្រតិកម្មធ្ងន់ធ្ងរ សូមជូនដំណឹងនេះដល់គ្រូពេទ្យរបស់អ្នក ជាបន្ទាន់**